# ភ័ស្តុតាងសញ្ជាតិ និងអត្តសញ្ញាណ(សម្គាល់ខ្លួន)

## សេចក្តីតម្រូវថ្មីសំរាប់ជនដែលទទួលផលប្រយោជន៍ម៉េឌីខាល់ Medi-Cal

### ដែលជាប្រជាពលរដ្ឋ ឬជនជាតិអាមេរិក

ច្បាប់ថ្មីចែងឡើងថា អ្នកទទួលផលប្រយោជន៍ម៉េឌីខាល់ Medi-Cal ភាគច្រើន ដែលជាពលរដ្ឋសហរដ្ឋអាមេរិក ឬជនជាតិអាមេរិក ត្រូវតែបង្ហាញភ័ស្តុតាងសញ្ជាតិ និងអត្តសញ្ញាណ។ សូមអានខាងក្រោមនេះ ដើម្បីអោយដឹងថា ច្បាប់នេះអនុវត្តដល់រូបអ្នក។

## បើសិនអ្នកពុំមែនជាប្រជាពលរដ្ឋសហរដ្ឋអាមេរិកនោះទេ ច្បាប់នេះពុំអនុវត្តដល់រូបអ្នកឡើយ។

**ច្បាប់ថ្មីពុំអនុវត្តឡើងចំពោះពលរដ្ឋសហរដ្ឋអាមេរិក និងជនជាតិអាមេរិក ដែលមានលក្ខណៈដូចផ្នែកណាមួយខាងក្រោមនេះ:**

- ជនដែលទទួល :
  - ប្រាក់ឧបត្ថម្ភ (SSI)
  - ម៉េឌីឃែរ Medicare
  - ប្រាក់ពិការ (SSDI)
  - ប្រាក់រ៉ឺត្រែត និងប្រាក់ធានារ៉ាប់រងសមាជិកគ្រួសារដែលទទួលអនិច្ចកម្ម (RSI – Title II) យោងទៅតាមភាពពិការរបស់ជននោះ
- ជនណាដែលមានអាយុក្រោម 21 ឆ្នាំ ដែលស្នើសុំសេវាអនុញ្ញាតសំរាប់ជនក្រោមអាយុ
- ទារករបស់ស្ត្រីដែលទទួលមេឌីខាល់ Medi-Cal
- ក្មេងរស់នៅក្នុងផ្នែកចិញ្ចឹមគ្រប់គ្រង ផ្នែកជំនួយសុំចិញ្ចឹម ឬផ្នែក Kin-GAP
- ទារកដែលនៅក្នុងកម្មវិធីបំបោះបំបង់ទារក
- ជនទទួលផលប្រយោជន៍ខាល់វ៉ឺត CalWORKs

### ចុះបើខ្ញុំពុំមែនជាជនដែលមានលក្ខណៈដូចជនខាងលើ នេះ?

បើអ្នកជាប្រជាពលរដ្ឋសហរដ្ឋអាមេរិក ឬជនជាតិអាមេរិក អ្នកត្រូវតែផ្តល់ភ័ស្តុតាងសញ្ជាតិ និងអត្តសញ្ញាណ ដើម្បីបន្តនូវសិទ្ធិទទួលម៉េឌីខាល់ Medi-Cal. (សូមអានទំព័រលេខ 3 ដើម្បីរកបញ្ជីរាយភ័ស្តុតាងសញ្ជាតិ និងអត្តសញ្ញាណដែលទទួលស្គាល់)។

ជនជាតិអាមេរិកមានរួមទាំងជនដែលកើតនៅទឹកដីអាមេរិកាំងសាម៉ូ (រួមទាំងកោះស្វែន Swains) និងជនជាតិខ្លះៗពីតំបន់កោះម៉ារីយ៉ាណា Mariana ខាងជើង។

### ចុះបើខ្ញុំពុំមែនជាពលរដ្ឋសហរដ្ឋអាមេរិក?

បើអ្នកពុំមែនជាពលរដ្ឋសហរដ្ឋអាមេរិក ឬជនជាតិ អ្នកនឹងត្រូវផ្តល់ឯកសារដែលតម្រូវឡើងដូចគ្រាមុន។ គ្មានអ្វីផ្លាស់ប្តូរទេ។

### តើការធានារ៉ាប់រងនេះបន្តទៅដល់កំណត់ពេលណា ដែរ?

ផលប្រយោជន៍ម៉េឌីខាល់ Medi-Cal របស់អ្នកនឹងបន្តបើសិនជាអ្នកមានលក្ខណៈសមស្របទៅតាមសេចក្តីតម្រូវនៃសិទ្ធិទទួលផ្សេងទៀត ហើយបានព្យាយាមដោយសមហេតុផល ក្នុងការផ្តល់ ភ័ស្តុតាង សញ្ជាតិ និងអត្តសញ្ញាណ។ អ្នកត្រូវតែផ្តល់ដំណឹងដល់បុគ្គលិកកាន់សុំណុំរឿងរបស់អ្នកថាអ្នកកំពុងសាកល្បងរកភ័ស្តុតាងនោះ។

### តើខ្ញុំអាចយកភ័ស្តុតាងសញ្ជាតិដោយវិធីណា?

បើសិនជាអ្នកកើតនៅរដ្ឋកាលីហ្វ័រនីញ៉ា ក្រសួងស្រុកអាចរក ឯកសារកំណើតបាន។ (ឯកសារកំណើតជាភ័ស្តុតាងសញ្ជាតិ)។

បំពេញក្រដាសស្នើសុំឯកសារកំណើតសំរាប់រដ្ឋកាលីហ្វ័រនីញ៉ា ដើម្បីស្នើសុំឯកសារកំណើតពីក្រសួងស្រុក។ រួចផ្ញើ ឬយកក្រដាសនេះទៅការិយាល័យក្រសួងសង្គមកិច្ចប្រចាំតំបន់របស់អ្នក។ បើសិនជាពុំអាចរកឯកសារកំណើតបាននោះទេ អ្នកត្រូវតែបង្ហាញភ័ស្តុតាងសញ្ជាតិផ្សេងមួយទៀត។ សូមអានទំព័រលេខ 3 ដើម្បីរកបញ្ជីរាយឯកសារដែលទទួលស្គាល់។

សួរក្រសួងស្រុកអំពីការរកភ័ស្តុតាងសញ្ជាតិ បើសិនជាអ្នកពុំកើតនៅក្នុងរដ្ឋកាលីហ្វ័រនីញ៉ា។ សូមទាក់ទងនិងក្រសួងស្រុកសួរគេបើសិនជាគេរកឃើញឯកសារកំណើតដែលត្រូវនិងរូបអ្នក មុននឹងអ្នកបង់ថ្លៃទៅលើប័ណ្ណបញ្ជីជាតិ។

### ចុះបើខ្ញុំពុំអាចផ្តល់ភ័ស្តុតាងសញ្ជាតិ ឬអត្តសញ្ញាណ?

អ្នកនឹងមានរយៈពេលសមហេតុផល ក្នុងការផ្តល់ភ័ស្តុតាងរបស់អ្នក។

បើសិនជាអ្នកពុំអាចផ្តល់ភ័ស្តុតាងបាន តែអ្នកនៅតែមានលក្ខណៈសមស្របទៅតាមសេចក្តីតម្រូវនៃសិទ្ធិទទួលផ្សេងទៀត ផលប្រយោជន៍របស់អ្នកនឹងប្តូរទៅផលប្រយោជន៍មានកំរិត។ ផលប្រយោជន៍មានកំរិត ធានារ៉ាប់រងភាពអាសន្ន សេវាទាក់ទងនិងភាពមានផ្ទៃពោះ និងសេវាថែទាំផ្សេងៗ ដែលត្រូវការពេលវេលាយូរ។

បើសិនជាអ្នកផ្តល់ភ័ស្តុតាង នៅក្នុងកំឡុងពេលមួយឆ្នាំនៅក្នុងកំណត់ខែសំរេចសិទ្ធិទទួលឡើងវិញ ផលប្រយោជន៍មេឌីខាល់ Medi-Cal របស់អ្នក នឹងប្តូរទៅផលប្រយោជន៍ពេញលេញចាប់តាំងពីកំណត់ថ្ងៃខែឆ្នាំដែលផលប្រយោជន៍មានកំរិតចាប់ផ្តើមដំណើរការឡើង។

បើសិនជាអ្នកបានចំណាយទៅលើសេវាសុខភាព នៅក្នុងកំឡុងពេលដែលអ្នករកឯកសារសញ្ជាតិ និងអត្តសញ្ញាណ មេឌីខាល់ Medi-Cal ប្រហែលជាបង់ថ្លៃទៅលើចំណាយនោះ។ សូមទូរស័ព្ទទៅផ្នែកសេវាផលប្រយោជន៍ នៃក្រសួងសុខាភិបាល ដើម្បីរកការឆ្លើយតបទៅនឹងសំណួររបស់អ្នក: (916) 403-2007។

### តើក្មេងត្រូវតែផ្តល់ភ័ស្តុតាងសញ្ជាតិ ឬអត្តសញ្ញាណដែរឬ?

ពិតហើយ។ បើសិនជាកូនរបស់អ្នកកើតនៅក្នុងរដ្ឋកាលីហ្វ័រនីញ៉ា សូមសួរក្រសួងស្រុករបស់អ្នក ដើម្បីស្នើសុំឯកសារកំណើត ប្រើជាភ័ស្តុតាងសញ្ជាតិ។ អ្នកនឹងនៅតែត្រូវផ្តល់ភ័ស្តុតាងសញ្ជាតិ។ សូមអានទំព័រលេខ 3។

បើសិនជាកូនរបស់អ្នកមានអាយុក្រោម 16 ឆ្នាំ ហើយអ្នកបានបំពេញ និងចុះហត្ថលេខាពាក្យសុំម៉េឌីខាល់ Medi-Cal ឬសុខភាពក្រុមគ្រួសារ Healthy Families/ម៉េឌីខាល់ Medi-Cal ពាក្យសុំរួមគ្នាដែលមានថ្ងៃខែឆ្នាំ និងទីកន្លែងកំណើតរបស់កូនអ្នក អ្នកពុំត្រូវការផ្តល់ភ័ស្តុតាងអត្តសញ្ញាណឡើយ។ (ពាក្យសុំដែលចុះហត្ថលេខានេះជាភ័ស្តុតាងសញ្ជាតិរបស់កូនអ្នក)។ អ្នកនឹងនៅតែត្រូវផ្តល់ភ័ស្តុតាងសញ្ជាតិ។

បើសិនជាកូនរបស់អ្នកមានអាយុ 16 ឆ្នាំ ឬលើសពី 16 ឆ្នាំ អ្នកត្រូវតែផ្តល់ភ័ស្តុតាងអត្តសញ្ញាណសំរាប់ក្មេងនោះ។ សូមអានទំព័រលេខ3។

### តើខ្ញុំត្រូវតែផ្តល់ភ័ស្តុតាងសញ្ជាតិ និងអត្តសញ្ញាណរៀង រាល់ពេលដែលខ្ញុំដាក់ពាក្យសុំឡើងវិញឬ?

ទេ។ អ្នកត្រូវផ្តល់ពតិមានទាំងនេះតែម្តងទេ - នៅពេលដែលអ្នកដាក់ពាក្យសុំជាដំបូង ឬនៅក្នុងពេលពិនិត្យសិទ្ធិទទួលឡើងវិញប្រចាំឆ្នាំ នៅលើកក្រោយ។

### តើច្បាប់នេះប៉ះពាល់ទៅដល់ផលប្រយោជន៍ហ្វ៊ិតស្តែម Food Stamps ខាល់វើគ CalWORKs ឬសុខភាពក្រុមគ្រួសារ Healthy Families របស់ខ្ញុំឬទេ?

ទេ។ សេចក្តីតម្រូវសញ្ជាតិ និងអត្តសញ្ញាណអនុវត្តចំពោះតែម៉េឌីខាល់ Medi-Cal ប៉ុណ្ណោះ។

### តើអ្នកត្រូវការឯកសារដើមនៃឯកសារសញ្ជាតិ និងអត្តសញ្ញាណឬ?

ពិតហើយ។ យើងត្រូវការឯកសារដើមនៃឯកសារសញ្ជាតិ និងអត្តសញ្ញាណ ឬឯកសារចម្លងដែលបញ្ជាក់ឡើងដោយក្រសួងដែលចេញក្រដាសនោះ។

### តើខ្ញុំអាចផ្ញើភ័ស្តុតាងរបស់ខ្ញុំតាមប៉ុស្តិ៍ប្រៃសណីយ៍បានឬទេ?

បាន។ ក្រសួងស្រុកនឹងចម្លងឯកសារនោះ ហើយផ្ញើក្រដាសនោះត្រឡប់អោយទៅរូបអ្នកវិញ។ ឬអ្នកអាចយកឯកសាររបស់អ្នកទៅការិយាល័យក្រសួងសង្គមកិច្ចប្រចាំតំបន់របស់អ្នក។ ស្នើសុំអោយគេថតចម្លង ហើយប្រគល់ឯកសារទាំងនោះអោយទៅរូបអ្នកវិញភ្លាម។

# ឯកសារសញ្ជាតិ និងអត្តសញ្ញាណដែលទទួលស្គាល់

វិធីដ៏ងាយស្រួលបំផុតសំរាប់ប្រជាពលរដ្ឋអាមេរិក ឬជនជាតិបង្ហាញភ័ស្តុតាងសញ្ជាតិ ឬអត្តសញ្ញាណ គឺផ្តល់ឯកសារ**ណាមួយ**នៃឯកសារទាំងនេះ:

— លិខិតឆ្លងដែន(ប៉ាស្ព័រ) សហរដ្ឋអាមេរិកដោយគ្មានកំណត់ពេល(ទទួលស្គាល់លិខិតផុតកំណត់)
— ប័ណ្ណចូលសញ្ជាតិ (N-550 ឬ N-570)
— ប័ណ្ណពលរដ្ឋអាមេរិក (N-560 ឬ N-561)

**— ឬ —**

បើសិនជាអ្នកពុំមានឯកសារណាមួយដូចខាងលើនេះទេ សូមផ្តល់...

## ឯកសារសញ្ជាតិមួយ ដូចមានរាយឡើងខាងក្រោមនេះ :

- ❖ ប័ណ្ណបញ្ជីជាតិសហរដ្ឋអាមេរិក
- ❖ ប័ណ្ណរាយការណ៍កំណើត (DS-1350)
- ❖ សេចក្តីរាយការណ៍កំណើតពលរដ្ឋអាមេរិកនៅបរទេស (FS-240)
- ❖ ប័ណ្ណបញ្ជីជាតិក្រសួងរដ្ឋាភិបាល (FS-545 ឬ DS-1350)
- ❖ ប័ណ្ណអត្តសញ្ញាណពលរដ្ឋអាមេរិក (I-197 ឬ I-179)
- ❖ ប័ណ្ណអាមេរិកាំងអ៊ិនឌៀន (I-872)
- ❖ ប័ណ្ណកោះម៉ារ៉ីយ៉ាណា Marianas ខាងជើង (I-873)
- ❖ ក្រិត្យសំរេចការសុំចិញ្ចឹមកូនមានបង្ហាញទីកំណើតនៅក្នុងសហរដ្ឋអាមេរិក
- ❖ ភ័ស្តុតាងស្នើសុំចិញ្ចឹមក្មេង ដែលកើតនៅក្រៅសហរដ្ឋអាមេរិក និងសិទ្ធិគ្រប់គ្រងតាមច្បាប់/ខ្លួនរបស់ឪពុកម្តាយដែលជាសញ្ជាតិអាមេរិកាំង (IR-3 ឬ IR-4)
- ❖ ភ័ស្តុតាងប្រកបការងាររដ្ឋការនៅសហរដ្ឋអាមេរិក មុនថ្ងៃទី 1 ខែមីនា ឆ្នាំ 1976
- ❖ ឯកសារយោធាសហរដ្ឋអាមេរិក បង្ហាញពីទីកន្លែងកំណើតនៅក្នុងសហរដ្ឋអាមេរិក
- ❖ ឯកសារមន្ទីរពេទ្យសហរដ្ឋអាមេរិក ដែលបានធ្វើឡើងនៅក្នុងពេលដែលជននោះកើតឡើង *†
- ❖ ឯកសារធានារ៉ាប់រងជីវិត សុខភាព ឬការធានាផ្សេងៗ *†
- ❖ ឯកសារសាសនា ចុះកំណត់នៅក្នុងសហរដ្ឋអាមេរិក នៅក្នុងកំឡុង 3 ខែ បង្ហាញពីទីកន្លែងកំណើតនៅក្នុងសហរដ្ឋ អាមេរិក និងថ្ងៃខែកំណើត ឬអាយុ
- ❖ ឯកសារសាលារៀនពីមុន ដែលបង្ហាញទីកន្លែងកំណើត កំណត់ថ្ងៃខែឆ្នាំចុះឈ្មោះចូលរៀន ឈ្មោះ និងទីកន្លែងកំណើត របស់ឪពុកម្តាយ
- ❖ ឯកសារស្រង់ចំនួនប្រជាជនសហព័ន្ធ ឬរដ្ឋ ដែលមានចុះកំណត់អាយុរបស់អ្នកដាក់ពាក្យសុំ សញ្ជាតិអាមេរិក ឬទីកំណើត
- ❖ ឯកសារស្រង់ចំនួនប្រជាជនកុលសម្ព័ន្ធសេណេការអ៊ិនឌៀន *†
- ❖ ឯកសារស្រង់ចំនួនប្រជាជនទីស្ដីការកុលសម្ព័ន្ធណាវ៉ាហ្វូអ៊ិនឌៀន *†
- ❖ សេចក្តីរាយការណ៍ពីស្ថិតិកំណើតដែលចុះបញ្ជីនៅក្នុងក្រសួងរក្សាឯកសារកំណើត នៅក្នុងរដ្ឋណាមួយនៃសហរដ្ឋអាមេរិក *†
- ❖ ការយឺតយ៉ាវក្នុងការចុះឯកសារកំណើតសាធារណៈសហរដ្ឋអាមេរិក (ដែលបានចុះនៅក្នុងបញ្ជីលើសពីចំនួន 5 ឆ្នាំ ចាប់ពីតាំងពីពេលដែលជននោះកើតឡើង) *†
- ❖ សេចក្តីថ្លែងចុះហត្ថលេខាដោយវេជ្ជបណ្ឌិត ឬឆ្មបដែលមានវត្តមាននៅក្នុងពេលកើត *†
- ❖ មុខងារនៅក្នុងសម្ព័ន្ធជនជាតិអាឡាស្កា ចេញពីក្រសួងកិច្ចការអ៊ិនឌៀន *†
- ❖ ក្រដាសចុះឈ្មោះចេញពីមណ្ឌលគិលានុបដ្ឋាក ឬមណ្ឌលជំនាញថែទាំ ឬគ្រឹះស្ថានដែលចុះកំណត់ពីទីកំណើតនៅក្នុងសហរដ្ឋអាមេរិក *
- ❖ ឯកសារសុខភាព (ពុំមែនឯកសារចាក់ថ្នាំបង្ការរោគទេ) *†

* ត្រូវតែចុះនៅក្នុងកំណត់យ៉ាងតិចបំផុតចំនួន 5 ឆ្នាំ មុនការដាក់ពាក្យសុំម៉េឌីខាល់ Medi-Cal ជាលើកដំបូងរបស់អ្នក ហើយមានចុះទីកន្លែងកំណើតនៅក្នុងសហរដ្ឋអាមេរិក។

†ចំពោះក្មេងអាយុក្រោម១៦ឆ្នាំ ត្រូវតែបង្កើតឡើងជិតកំណត់ពេលកើតឡើង។

អ្នក**ត្រូវតែ**ផ្តល់ឯកសារណាមួយ ទៅតាមកំរិតមុនគេបង្អស់ដូចមានរាយឡើង ទៅតាមការដែលអ្នកអាចធ្វើបាន។

បើសិនជាអ្នក**ពុំអាច**ផ្តល់ឯកសារណាមួយនៃឯកសារសញ្ជាតិនេះទេ...

សូមសុំអោយជនពេញវ័យពីររូបបំពេញ ហើយចុះហត្ថលេខានៅក្នុងក្រដាសធានាសញ្ជាតិ។ ជនពេញវ័យទាំងពីររូបត្រូវតែមានភ័ស្តុតាងអត្តសញ្ញាណរបស់ខ្លួន និងឯកសារពលរដ្ឋសហរដ្ឋអាមេរិក ហើយជនតែម្នាក់ទេ ដែលត្រូវតែជាប់សាច់ញាតិជាមួយនិងរូបអ្នក។

**— និង —**

## ឯកសារអត្តសញ្ញាណមួយ ដូចមានរាយឡើងខាងក្រោមនេះ :

- ❖ ប័ណ្ណបើកបរអនុញ្ញាតចេញអោយប្រើប្រាស់ដោយក្រសួងសហរដ្ឋអាមេរិក ឬតំបន់កាន់កាប់ ដែលមានរូបថត ឬពត៌មានសម្គាល់អត្តសញ្ញាណ
- ❖ ប័ណ្ណសាលារៀនដែលមានរូបថត
- ❖ ប័ណ្ណយោធា ឬឯកសារជ្រើសរើសយោធាអាមេរិក
- ❖ ប័ណ្ណសហព័ន្ធ រដ្ឋ ឬរដ្ឋាភិបាលប្រចាំតំបន់ ដែលមានពត៌មានដូចគ្នា និងប័ណ្ណបើកបរ
- ❖ ប័ណ្ណអត្តសញ្ញាណជនក្នុងបន្ទុកយោធាសហរដ្ឋអាមេរិក
- ❖ លិខិតឆ្លងដែនសហរដ្ឋអាមេរិក (ចេញអោយប្រើដោយមានកំណត់)

- ❖ ប័ណ្ណក្រិត្យខ្សែស្រឡាយជនជាតិអ៊ិនឌៀន ឬជនជាតិអាមេរិកាំងអ៊ិនឌៀន/ឯកសារកុលសម្ព័ន្ធជនជាតិអាឡាស្កា
- ❖ ប័ណ្ណកងទ័ពការពារពាណិជ្ជកម្មឆ្នេរសមុទ្រសហរដ្ឋអាមេរិក
- ❖ ឯកសារបី ឬលើសពីបី ដូចជាប័ណ្ណបុគ្គលិក សញ្ញាប័ត្រវិទ្យាល័យ ឬមហាវិទ្យាល័យ ប័ណ្ណអេតាស៊ីវិល(រៀបការ) ក្រិត លែងលះគ្នា និងសំបុត្រផ្លាស់ឈ្មោះ/សំបុត្រសិទ្ធិទ្រព្យសម្បត្តិ
- ❖ ឯកសារមន្ទីរព្យាបាល វេជ្ជបណ្ឌិត ឬមន្ទីរពេទ្យសំរាប់ក្មេងអាយុក្រោម 16 ឆ្នាំ
- ❖ សាលារៀន មត្តេយ្យសាលា ឬឯកសារទីមើលក្មេង មានរួមទាំងប័ណ្ណរាយការណ៍ពិន្ទុ សំរាប់ក្មេងអាយុក្រោម 16 ឆ្នាំ។ ក្រសួងស្រុកនឹងធ្វើការបញ្ជាក់ជាមួយនិងសាលារៀន។
- ❖ ចំពោះជនពិការ ដែលរស់នៅមណ្ឌលថែទាំ ត្រូវមានសេចក្តីធានាអះអាងដែលចុះហត្ថលេខា ដោយនាយកចាត់ការ មណ្ឌល ឬអ្នកដឹកនាំ។

**ចំពោះក្មេងអាយុក្រោម 16 ឆ្នាំ** ដែលពុំមានលិខិតបញ្ជាក់សញ្ជាតិ អ្នកអាចបញ្ជូន:

- ❖ សេចក្តីធានាអះអាងអត្តសញ្ញាណរបស់ក្មេង ដែលចុះហត្ថលេខាដោយឪពុកម្តាយ អ្នកអាណាព្យាបាល ឬសាច់ញាតិ ដែលថែទាំក្មេង មានចុះថ្ងៃខែឆ្នាំ និងទីកន្លែងកំណើត
- ❖ ពាក្យសុំម៉េឌីខាល់ Medi-Cal ឬ Healthy Families/Medi-Cal ពាក្យសុំរួមគ្នា ដែលបង្ហាញថ្ងៃខែឆ្នាំ និងទីកន្លែងកំណើតរបស់ក្មេង និងចុះហត្ថលេខាដោយឪពុកម្តាយ អ្នកអាណាព្យាបាល ឬសាច់ញាតិដែលថែទាំក្មេង។

**ចំពោះក្មេងអាយុក្រោម 18 ឆ្នាំ** លិខិតបញ្ជាក់អត្តសញ្ញាណ ចុះហត្ថលេខាដោយឪពុកម្តាយ អ្នកអាណាព្យាបាល ឬ សាច់ញាតិ អាចយកមកប្រើ បើសិនជាពុំមានប័ណ្ណសាលារៀន ឬប័ណ្ណបើកបរ។

កំណត់សម្គាល់: ឯកសារអត្តសញ្ញាណដែលផុតថ្ងៃ ទទួលស្គាល់ជាភ័ស្តុតាងអត្តសញ្ញាណ។